ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីដែនជម្រកសត្វព្រៃរនាមដូនសំ និងគម្រោងដីសម្បទានសេដ្ឋកិច្ច នូវផ្ទៃដីទំហំ ២.៦៦៧,៩០ ហិកតា នៅភូមិទួលក្រសាំង ភូមិអូរគគរ ភូមិគំនរបេង និងភូមិអូរគ្រាចជុ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង និងធ្វើប្រទានកម្មផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិទួលក្រសាំង ឃុំសិរីមានជ័យ ស្រុកសំពៅលូន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ១១៩៩ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- តាមសំណើលេខ ១២៥១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញនូវផ្ទៃដីសរុបទំហំ ២.៦៦៧,៩០ ហិកតា ក្នុងនោះកាត់ចេញពីដែនជម្រកសត្វព្រៃរនាមដូនសំ (ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣) ដើម្បីធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦៨៨,៦៥ ហិកតា និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន សួន មាន សម្បត្តិ ខូ.អិលធីឌី (អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល) នូវផ្ទៃដីទំហំ ១.៩៧៩,២៥ ហិកតា សម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋ ១.៦៤៨ គ្រួសារ ស្ថិតនៅភូមិទួលក្រសាំង ភូមិអូរគគីរ ភូមិគំនរបេង និងភូមិអូរគ្រាវជូ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណាត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មដោយផ្តល់នូវសិទ្ធិជាកម្មសិទ្ធិឯកជន ជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិទួលក្រសាំង ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង លើក្បាលដីចំនួន ៣១៣ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២២៩ គ្រួសារ ចំពោះក្បាលដីចំនួន ៣១៣ ក្បាលដី កម្មសិទ្ធិលើដីវត្ត ចំនួន ០១ ក្បាលដី និង ០៣ ក្បាលដីជាដីរដ្ឋរួមមានដីសាលារៀន ០១ ក្បាលដី ដីស្នាក់ការភូមិ ០១ ក្បាលដី ដីអណ្តូងទឹករួម ០១ ក្បាលដី។

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

**មាត្រា ៤ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*